# ក្រុមប្រាសាទស្រីគ្រប់លក្ខណ៍

ស្រីគ្រប់លក្ខណ៍ គឺជាឈ្មោះក្រុមប្រាសាទមួយដែលស្ថិតនៅក្នុងតំបន់ប្រាសាទសំបូរព្រៃគុក ចម្ងាយប្រមាណ២គីឡូម៉ែត្រខាងជើងក្រុមប្រាសាទសំខាន់ៗទាំងបីក្រុម និងស្ថិតនៅចម្ងាយ ១០០ម៉ែត្រខាងកើតក្រុមប្រាសាទរបងរមាស។ ក្រុមប្រាសាទនេះ ធ្លាប់មានអ្នកស្រាវជ្រាវជំនាន់មុនសិក្សាច្រើនមកហើយ ប៉ុន្តែពេលនោះគេមិនបានកត់ត្រាឈ្មោះនេះឡើយ ដោយប្រើឈ្មោះហៅសម្គាល់ថា "ក្រុមប្រាសាទដែលនៅជិតរបងរមាស" ពោល គឺគេយកឈ្មោះ "របងរមាស" ជាគោល[1]។ ឈ្មោះដែលយើងស្គាល់សព្វថ្ងៃនេះ យើងមិនដឹងច្បាស់ថាកើតចេញពីពេលណាមកទេ ប៉ុន្តែអ្នកស្រុកចំណាស់ៗដែលកំពុងរស់នៅតំបន់នោះ ចងចាំថាឈ្មោះ "ស្រីគ្រប់លក្ខណ៍" គេហៅសំដៅទៅលើរូបស្ត្រីគ្រប់លក្ខណ៍ដែលឆ្លាក់នៅលើផ្ដែរទ្វារមួយនៅតួប៉ម L4។ ផ្ដែរទ្វារនោះ គឺឆ្លាក់បង្ហាញពីរឿងព្រះវិស្ណុផ្ទំលើនាគអនន្តរង់ចាំបង្កើតលោកថ្មី ដែលជានិច្ចកាលសិល្បករបុរាណខ្មែរតែងឆ្លាក់ព្រះនាងលក្ស្មី (មហេសីព្រះវិស្ណុ) នៅចុងព្រះបាទរបស់ព្រះវិស្ណុ។ ម្ល៉ោះហើយ នៅពេលអ្នកស្រុកឃើញផ្ដែរទ្វារនោះ ក៏ហៅប្រាសាទនេះថា "ស្រីគ្រប់លក្ខណ៍" តែម្ដង (រូបលេខ១)។

ក្រុមប្រាសាទស្រីគ្រប់លក្ខណ៍ មានប្រាសាទចំនួន ៧ ដែលក្រុមស្រាវជ្រាវរបស់សាកលវិទ្យាល័យវ៉ាសេដា តាងដោយអក្សរ L1 រហូតដល់ L7។ ក្នុងនោះ តួប៉ម L1, L2, L3 បានបាក់បែកច្រើន ហើយសុទ្ធសឹងជាសំណង់ដែលសាងឡើងនៅសម័យអង្គរ នាស.វ.ទី១១។ ចំណែក តួប៉ម L4 វិញ នៅរក្សារូបរាងដើមបានល្អ ដែលជាសំណង់សាងឡើងអំពីឥដ្ឋ បែរមុខទៅទិសខាងកើត មានរាងបួនជ្រុងស្មើ សាងឡើងនៅសម័យមុនអង្គរ ក្នុងរចនាបថព្រៃក្មេង នាស.វ.ទី៧ (រូបលេខ២) ហើយមានទីតាំងស្ថិតនៅចំកណ្ដាលរវាងតួប៉ម L1,L2,L3 និង L5, L6, L7។

ក្រៅពីនេះ មានតួប៉មដែលសំខាន់ជាងគេនៅក្នុងក្រុមគឺ តួប៉ម L5។ តួប៉មនេះសាងឡើងអំពីឥដ្ឋ មានរាងបួនជ្រុងស្មើ បែរមុខទៅកើត ដែលសាងនៅស.វ.ទី៧ ប៉ុន្តែក្រោយមកគេបានសាងជាយ៉បន្ថែមនិងកែប្រែប្លង់មួយចំនួននៅស.វ.ទី១១ ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២ - ១០៤៩) (រូបលេខ៣)។ ដើម្បីឲ្យប្លង់មានលក្ខណៈស្របទៅនឹងបរិបទស្ថាបត្យកម្មស.វ.ទី១១ គេបានសាងឱ្យមានជាហោរត្រៃមួយស្ថិតនៅទិសអាគ្នេយ៍តួប៉ម L5។ ហោរត្រៃនេះគេសាងបែរមុខបញ្ច្រាសពីប្រាសាទសំខាន់នៅកណ្ដាល ពោល គឺបែរមុខទៅទិសខាងលិច ហើយសំណង់នេះដែរអ្នកស្រាវជ្រាវបានចុះបញ្ជីជាតួប៉ម L7 (រូបលេខ៤)។ ជាងនេះទៀតគេបានសាងកំពែង និង

[1] Parmentier 1913: 31-32.

អត្ថបទដោយៈ ម៉ង់ វ៉ាលី

ខ្លោងទ្វារនៅទល់មុខតួប៉ម L5 ទៀតផង ក្នុងន័យដូចបានជម្រាបជូនខាងលើ ពោល គឺឲ្យស្របនឹងប្លង់ទូទៅនៃស.វ.ទី១១[2] (រូបលេខ៥)។ សំណង់ប្រាសាទសំខាន់ចុះបញ្ជីលេខ L5 នេះ សិល្បករលម្អជាក្បាច់ជាច្រើននៅតាមក្បាលជញ្ជាំង ជាពិសេសគឺក្បាច់គុឌុ ឬហៅថាកូនបង្អួច ដែលជាក្បាច់តំណាងឲ្យភាពខ្ពង់ខ្ពស់តាមគំនិតដែលខ្មែរបានទទួលពីឥណ្ឌា នៅស.វ.ទី៧[3] (រូបលេខ៦)។

លក្ខណៈពិសេសមួយទៀតរបស់តួប៉មនេះ គឺគេបានរកឃើញសិលាចារឹកនៅលើមេទ្វារយ៉ខាងមុខ ដែលចារជាភាសាសំស្ក្រឹតចំនួន ១២ ស្លោក ស្មើនឹង ២៤ បន្ទាត់។ សិលាចារឹកនេះ ចុះបញ្ជីលេខ K.151[4] ចារឹកឡើងនៅស.វ.ទី៧ ដែលលោក Michael Vickery យល់ថាអាចទំនងចារឡើងនៅចុងរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ ឬមិនយូរប៉ុន្មានក្រោយការសុគតរបស់ទ្រង់ ពោល គឺដើមរជ្ជកាលព្រះបាទភវវរ្ម័នទី២[5]។ ប្រការដែលគួរឲ្យមានចម្ងល់នោះគឺ មេទ្វារដែលមានចារឹកនេះគេយកមកសាងបន្ថែមនៅយ៉ខាងមុខរបស់ប្រាសាទ ដែលមានន័យថា សិលាចារឹកនេះមិនមែនជាសិលាចារឹកដើមរបស់ប្រាសាទទេ ពោល គឺជាមេទ្វារដែលមានអក្សរស្រាប់ចារនៅស.វ.ទីដែលគេយកមកពីទីកន្លែងណាមួយផ្សេង ហើយយកមកធ្វើជាមេទ្វាររបស់យ៉ប្រាសាទនេះនៅក្នុងស.វ.ទី១១។ ខ្លឹមសារនៃសិលាចារឹកនេះរៀបរាប់អំពី "មន្ត្រីម្នាក់ឈ្មោះ នរសិង្ហគុប្ត ដែលជាមន្ត្រីម្នាក់ធ្លាប់បម្រើស្តេចបីអង្គ គឺព្រះបាទភវវរ្ម័នទី១ ព្រះបាទមហេន្ទ្រវរ្ម័ន និងព្រះបាទឦសានវរ្ម័នទី១ (បន្ទាត់ទី២-៤) ហើយមន្ត្រីរូបនេះ ជាស្តេចត្រាញ់ឬមន្ត្រីជាន់ខ្ពស់នៅក្រុងឥន្ទ្របុរៈដែរ (បន្ទាត់ទី៥) នៅមហាសករាជឆ្នាំ៥២០ ត្រូវនឹងគ.ស.ឆ្នាំ៥៩៨ គាត់បានកសាងបដិមាព្រះវិស្ណុមួយឈ្មោះត្រីកបិលវាសុទេវ(បន្ទាត់ទី៧-៨) ហើយបានបង្កើតក្រុងមួយឬពីរនៅខាងត្បូងប្រាសាទដាក់ឈ្មោះថាត្រីកបិល ដែលមានទាំងដីភូមិ ដីស្រែ និងអ្នកបម្រើនៅទីនោះ (បន្ទាត់ទី១៩-២០)។ នៅខាងកើតប្រាសាទមានអូរឬប្រឡាយ អាគ្នេយ៍មានស្ទឹង ខាងជើងជាផ្លូវធំឈ្មោះថាតំបន់ព្រៃកណ្តាល[6]។

ជារួមមក ក្រុមប្រាសាទស្រីគ្រប់លក្ខណ៍ គឺជាសំណង់ប្រាសាទមួយដែលទំនងសាងឡើងនៅពីរដំណាក់កាលផ្សេងគ្នា ពោល ដំណាក់កាលទី១នៅស.វ.ទី៧ រចនាបថព្រៃក្មេង អាចក្នុង

(2) ច័ន្ទ វិត្ថារ៉ុង ២០០៨: ៨៣។

(3) Bénisti 1970: 15.

(4) Coedès 1943: 5.

(5) Vickery 1998: 327.

(6) Coedès 1943: 5.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

រជ្ជកាលព្រះបាទភវវរ្ម័នទី២ ហើយសាងសង់បន្ថែមក្រោយនៅស.វ.ទី១១ ទំនងក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១។ សំណង់បូជនីយដ្ឋានរួមនៅក្នុងក្រុមប្រាសាទនេះ មានលក្ខណៈស្មុគស្មាញ ដែលពិបាកក្នុងការសិក្សាឲ្យបានច្បាស់ ជាពិសេស គឺនៅតួប៉ម L1, L2, L3។

## ឯកសារយោង


**ច័ន្ទ វិត្ថារ៉ុង**

២០០៨, *បូជនីយដ្ឋានមួយដែលឆ្លងកាត់ច្រើនសម័យកាល (ករណីសិក្សាប្រាសាទស្រីគ្រប់លក្ខណ៍នៅសំបូរព្រៃគុក, កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, លេខ ៤, ភ្នំពេញ*

**Bénisti, Mireille**

1970, *"Rapports entre le premier art Khmer et l'art Indien"* EFEO, Tome I-II, Paris

**Coedès, George**

1943: "Quelque précisions sur la fin du Fou-Nan" *BEFEO*, Tome 43, Paris

**Parmentier, Henri**

1913, "Complément à l'Inventaire descriptif des monuments du Cambodge", *BEFEO*, Tome 13, Paris

**Vickery, Michael**

1998, *Society, Economic and Politics in pre-Angkor Cambodia, 7$^{th}$ - 8$^{th}$ centuries*, Tokyo.




*រូបលេខ១៖ ផ្តែរទ្វារខាងកើតនៃតួប៉ម L5 (ប្រភព៖ Bénisti, Mireille, 1974)*

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៖ ប្រាសាទស្រីគ្រប់ល័ក្ខណា តួប៉ម L4 (មើលពីមុខឦសាន)



រូបលេខ៣៖ ប្រាសាទស្រីគ្រប់ល័ក្ខណា តួប៉ម L5 (មើលទិសអាគ្នេយ៍)



រូបលេខ៣៖ ប្រាសាទស្រីគ្រប់លក្ខណ៍ តួប៉ម L5 (មើលទិសនិរតី)



រូបលេខ៤៖ ប្រាសាទស្រីគ្រប់លក្ខណ៍ តួប៉ម L7 (មើលពីមុខខាងលិច)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៥៖ ប្រាសាទស្រីគ្រប់ល័ក្ខណា តួប៉ម L6 (មើលពីមុខខាងលិច)



រូបលេខ៦៖ ចម្លាក់កូនបង្អួចបុគុឌុលម្ពនៅផ្នែកខាងលើ តួប៉ម L5

អត្ថបទដោយ៖ ម៉ង់ រ៉ាលី